# សង្ខេប


កាលពីខែ មីនា ឆ្នាំ ២០២០ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (ដែលហៅកាត់ថា UNDP) បានប្រកាសអនុវត្តគម្រោងមួយដែលមានឈ្មោះថា "កសាងសមត្ថភាពដើម្បីជំរុញការចូលរួមរបស់ពលរដ្ឋ ការកសាងសន្តិភាព និងកិច្ចសន្ទនាប្រកបដោយបរិយាប័ន្នៈ ឆ្ពោះទៅអភិបាលកិច្ចបែបបរិយាប័ន្ន និងមានការចូលរួម" (ហៅកាត់ថា គម្រោង)។ គម្រោងនេះនឹងបន្តអនុវត្តរហូតដល់ចុងឆ្នាំ ២០២៣។ គម្រោងនេះនឹងត្រូវអនុវត្តដោយ UNDP ដោយប្រើប្រាស់ការទម្រង់អនុវត្តផ្ទាល់ (DIM) ជាមួយការគាំទ្រថវិកាពី រដ្ឋាភិបាលជប៉ុន (GoJ) និង UNDP ។ អភិបាលកិច្ចលើគម្រោងនេះធ្វើឡើងដោយក្រុមប្រឹក្សាភិបាលគម្រោង ដែលមានសមាសភាពជាតំណាងមកពី UNDP រដ្ឋាភិបាលជប៉ុន ក្រសួងមហាផ្ទៃ និងអង្គការ សម្ព័ន្ធការពារសិទ្ធិមនុស្សនៅកម្ពុជា (CHRAC) ដែលជាអង្គការក្រៅរដ្ឋាភិបាល។ ក្រុមប្រឹក្សាភិបាលនេះគឺជាស្ថាប័នអភិបាលកិច្ចរបស់គម្រោង និងទទួលខុសត្រូវផ្តល់ការណែនាំកម្រិតយុទ្ធសាស្ត្រ និងអនុម័តលើសកម្មភាពរបស់គម្រោង។ ក្រុមអនុវត្តគម្រោងដឹកនាំដោយប្រធានទីប្រឹក្សាបច្ចេកទេស។ ប្រធានទីប្រឹក្សាបច្ចេកទេសជាអ្នកគ្រប់គ្រងហានិភ័យគម្រោង រួមគ្នាជាមួយនឹងអ្នកសម្របសម្រួលបច្ចេកទេស និងត្រូវធានាឱ្យមានភាពអនុលោមតាមស្តង់ដារសង្គម និងបរិស្ថានរបស់ UNDP។

គោលដៅរួមនៃគម្រោងនេះ គឺដើម្បីលើកកម្ពស់គំនិតផ្តួចផ្តើមអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងសង្គមប្រកបដោយសន្តិភាព បរិយាប័ន្ន និងសមធម៌ តាមរយៈការពង្រីកឱកាសចូលរួមបែបបរិយាប័ន្នរបស់ពលរដ្ឋ ដោយប្រើប្រាស់យន្តការកិច្ចសន្ទនា។

គម្រោងនេះមានសកម្មភាពដូចខាងក្រោម ដែលនឹងត្រូវរៀបរាប់លម្អិតនៅក្នុងឯកសារគម្រោង (ProDoc)៖

១.១ អភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៅតាមក្រសួងពាក់ព័ន្ធ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

១.២ អភិវឌ្ឍសមត្ថភាពអង្គការសង្គមស៊ីវិល

១.៣ រៀបចំឧបករណ៍ និងអភិវឌ្ឍចំណេះដឹង ដើម្បីឈ្វេងយល់ពីផលប្រយោជន៍របស់ពលរដ្ឋទាំងប្រុសទាំងស្រី ជាពិសេសក្រុមដែលមានឱកាសតិចតួច

២.១ ផ្តល់អ្នកផ្សះផ្សារ និងអ្នកសម្របសម្រួល

២.២ ធ្វើស្ថាប័ននីយតកម្មហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ សម្រាប់ការចូលរួមរបស់ពលរដ្ឋ និងគាំទ្រដល់ការអនុវត្តផែនការសកម្មភាព

២.៣ រៀបចំ ផលិតផលអប់រំផ្សព្វផ្សាយ និងគ្រប់គ្រងចំណេះដឹង

៣.១ រៀបចំកម្មវិធីប្រកួតប្រជែងនវានុវត្តន៍ជំរុញការចូលរួមរបស់ពលរដ្ឋ

៣.២ រៀបចំដំណើរទស្សនកិច្ចសិក្សា។

ខណៈពេលដែលពីដំបូងគម្រោងនេះត្រូវបាន កំណត់ថាមានហានិភ័យ "ទាប" កាលពីខែ មីនា ឆ្នាំ ២០២០ នីតិវិធីពិនិត្យបឋមលើបញ្ហាសង្គមនិងបរិស្ថាន (SESP) ដែលត្រូវបានធ្វើបច្ចុប្បន្នភាពផ្អែកតាមការកែសម្រួលការរចនាគម្រោង រៀបចំកិច្ចពិគ្រោះយោបល់និងផ្អែកតាមលទ្ធផលនៃដំណាក់កាលចាប់ផ្តើមគម្រោង មានការវាយតម្លៃឃើញថា គម្រោងនេះមានហានិភ័យ "ខ្ពស់មធ្យម (substantial)" ដែលនាំឱ្យចាំបាច់ត្រូវធ្វើការវាយតម្លៃលើផលប៉ះពាល់បរិស្ថានសង្គម (ESIA) និងការរៀបចំផែនការគ្រប់គ្រង បរិស្ថាន និងសង្គម (ESMP)។ ហានិភ័យដែលត្រូវបានកំណត់រកឃើញពាក់ព័ន្ធជាចម្បងជាមួយនឹងសិទ្ធិមនុស្សនិងផលប៉ះពាល់សង្គម ហើយ ESIA (ហៅថា SIA ក្នុងឯកសារនេះ) មានបំណងវាយតម្លៃលើហានិភ័យនិងផលប៉ះពាល់ទាំងនេះ និងដាក់ចេញវិធានការដើម្បីបញ្ចៀស ឬកាត់បន្ថយហានិភ័យនិងផលប៉ះពាល់ទាំងនេះឱ្យនៅតិចដែលជាអប្បបរមា ឬប្រសិនបើមិនអាចធ្វើទៅបាន សម្រាលហានិភ័យនិងផលប៉ះពាល់ទាំងនេះ។ ពង្រាង SIA រៀបរាប់ពីៈ

- សកម្មភាពរបស់គម្រោង
- ក្របខ័ណ្ឌច្បាប់របស់ប្រទេស ព្រមទាំងគោលការណ៍ និងស្តង់ដារពាក់ព័ន្ធរបស់ UNDP
- ការវិភាគទៅលើអត្ថប្រយោជន៍ ប៉ុន្តែផ្តោតជាពិសេសលើហានិភ័យនិងផលប៉ះពាល់ដែលបង្កឡើងដោយសារគម្រោងទៅតាមសកម្មភាពគម្រោងនិងទៅតាមបរិបទសង្គម ព្រមទាំងការពិនិត្យ លើវិធីសាស្ត្រដើម្បីសម្រាលហានិភ័យ/ផលប៉ះពាល់ ឬកំណត់ពីជម្រើសដែលអាចមានសម្រាប់គម្រោង
- ការបង្ហាញដោយសង្ខេបពីលទ្ធផលនៃការវិភាគអ្នកពាក់ព័ន្ធ ដែលនឹងត្រូវរៀបរាប់លម្អិតបន្ថែមទៀតនៅក្នុងផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ ដែលត្រូវបានរៀបចំសម្រាប់គម្រោងនេះ។

ការវាយតម្លៃ SIA រកឃើញថា គម្រោងនេះអាចផ្តល់ប្រយោជន៍ដល់អង្គការសង្គមស៊ីវិលផង និង. រដ្ឋាភិបាលផង ចេញពីសមាសភាគកសាងសមត្ថភាពនៅក្នុងគម្រោង ដូចជា ការអភិវឌ្ឍកម្មវិធីសិក្សា (សកម្មភាព ១.១) ដំណើរទស្សនកិច្ចសិក្សា (សកម្មភាព ៣.២) និងការគាំទ្រដល់អង្គការសង្គមស៊ីវិល

ក្នុងការបង្កើនភាពធន់និងនិរន្តរភាពរយៈពេលវែង (សកម្មភាព ១.២)។ គម្រោងនេះក៏អាចផ្តល់ជាប្រយោជន៍ដល់អង្គការសង្គមស៊ីវិលតូចៗ តាមរយៈការកសាងសមត្ថភាពរបស់ពួកគេ (សកម្មភាព ១.២) ដែលអាចជួយដល់ការអនុវត្តសកម្មភាពនៅថ្នាក់ខេត្ត សំរាប់អង្គការតូចៗដែលជួបប្រទះនឹងបញ្ហាខ្វះថវិកា ដូចការរៀបរាប់ពីខាងដើមនៅក្នុងរបាយការណ៍នេះ។
អត្ថប្រយោជន៍ដែលបានពីការគាំទ្រដល់សកម្មភាពទាំងនេះ ត្រូវបានរៀបរាប់លម្អិតនៅក្នុងឯកសារគម្រោង (ProDoc)។

ផ្អែកតាមទិន្នន័យដើមគ្រារបស់គម្រោង ឯកសារគម្រោងនិងស្តង់ដារសង្គមបរិស្ថាន (SES) របស់ UNDP ការវាយតម្លៃ SIA នេះ រកឃើញថាគម្រោងទាំងមូលគួរចុះប្រភេទថា "ខ្ពស់" ទៅតាមការណែនាំអំពី SESP របស់ UNDP ព្រោះថាសកម្មភាពរបស់គម្រោងអាចនាំឱ្យមានហានិភ័យ និងផលប៉ះពាល់សង្គមក្នុងកម្រិតមធ្យម (moderate) ខ្ពស់មធ្យម (substantial) និងខ្ពស់ខ្លាំង (high)។ ហានិភ័យទាំងនេះអាចទំនងជាបង្កផលប៉ះពាល់អវិជ្ជមានលើក្រុមងាយរងគ្រោះ ឬក្រុមដែលមានឱកាសតិចតួច ដូចជា ស្ត្រី ជនក្រីក្រ ក្រុមជនជាតិដើមភាគតិច ជនជាតិភាគតិច និងសកម្មជនគ្រប់ប្រភេទទាំងអស់៖

១. **ហានិភ័យ ធម្យមនៃអំពីការឆ្លងរាលដាលជំងឺកូវីដ-១៩**
ដែលកើតឡើងចេញពីសកម្មភាពបណ្តុះបណ្តាល និងសកម្មភាពផ្សេងទៀតរបស់គម្រោង និងនៃការបៀតបៀនផ្លូវភេទក្នុងអំឡុងពេលនៃការអនុវត្តសកម្មភាព។

២. **ហានិភ័យមធ្យមនៃការចូលរួមរបស់ស្ត្រីនៅមានកម្រិត**

ដោយសារមន្ត្រីរាជការជាស្ត្រីមានចំនួនតិចហើយដោយហេតុថាស្ត្រីដែលកាន់មុខតំណែងជាអ្នកដឹកនាំ ក្នុងជួរអង្គការសង្គមស៊ីវិលក៏មានចំនួនតិចតួចផងដែរនោះ អាចថានឹងមិនមានស្ត្រីច្រើននាក់នោះឡើយនឹងទទួលបានប្រយោជន៍ពីសកម្មភាពគម្រោង ឬអាចចូលរួមនៅក្នុងសកម្មភាពគម្រោង។

៣. **ហានិភ័យខ្ពស់ខ្លាំងនៃការខកខានមិនបានបញ្ចូលតួអង្គពាក់ព័ន្ធ**
ដោយសារអង្គការសង្គមស៊ីវិលមួយចំនួនមានភាពស្ទាក់ស្ទើរក្នុងការចូលរួមជាមួយគម្រោង ដោយសារតែបរិបទសង្គមនយោបាយនៅកម្ពុជា។

៤. **ហានិភ័យ ខ្ពស់មធ្យមនៃការបង្កើត វេទិកាដែលផ្តល់ភាពស្របច្បាប់ដល់រដ្ឋាភិបាល ភាពជឿទុកចិត្តបាន និងការបញ្ជាក់សុពលភាពនៃកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងដៃគូអង្គការសង្គមស៊ីវិលបច្ចុប្បន្ន** ដែលផ្តល់នូវភស្តុតាងបញ្ជាក់ថា មានការឆ្លើយតបយ៉ាងពេញលេញចំពោះសិទ្ធិចូលរួមនៅកម្ពុជា។ នេះអាចការធ្វើឱ្យប៉ះពាល់ដល់អ្នកដែលកំពុងស្វែងរកការគាំទ្រឱ្យមានការការពារកាន់តែប្រសើរ សម្រាប់បញ្ហាទាក់ទិននឹងការចូលរួម និងសិទ្ធិមនុស្ស។

៥. **ហានិភ័យមធ្យមអាចថាអ្នកចូលរួមគម្រោងមិនបានទទួលព័ត៌មានឱ្យបានគ្រប់គ្រាន់** ព្រោះតែមានការចែករំលែកព័ត៌មាននៅមានកម្រិត ដែលអាចកាត់បន្ថយលទ្ធភាពរបស់តួអង្គពាក់ព័ន្ធ ដើម្បីចូលរួមក្នុងគម្រោងនិងទទួលបានប្រយោជន៍ពីគម្រោង ព្រមទាំងអាចបង្ហាញពីការបារម្ភ ឬផ្តល់មតិ ត្រឡប់ជុំវិញសកម្មភាពរបស់គម្រោង។

៦. **ហានិភ័យមធ្យមនៃផលប៉ះពាល់អវិជ្ជមានមកលើសិទ្ធិរបស់ជនជាតិដើមភាគតិច។** ការរចនាគម្រោងនេះផ្តោតលើខេត្តយ៉ាងហោចណាស់មួយនៅក្នុងតំបន់ខ្ពង់រាប ដែលជាទូទៅគឺជាកន្លែងដែលមានក្រុមជនជាតិដើមភាគតិចរស់នៅ។ ក្រុមជនជាតិដើមភាគតិចនឹងទទួលរងហានិភ័យដូចរៀបរាប់ខាងលើដែរ (១-៥) ដូច្នេះសិទ្ធិរបស់ពួកគេក៏រងផលប៉ះពាល់ផងដែរ។

### តារាងទី ១៖ ហានិភ័យ និងផលប៉ះពាល់អវិជ្ជមានដែលអាចកើតចេញពីសកម្មភាពគម្រោង

| សមាសភាគ [1] | ហានិភ័យ | ផលប៉ះពាល់ | ស្តង់ដារសង្គមបរិស្ថានរបស់ UNDP | លទ្ធភាពដែលអាចកើតមានឡើង និងកម្រិតគួរឱ្យកត់សម្គាល់របស់វា[2] | វិធានការសម្រាលផលប៉ះពាល់ | ការទទួលខុសត្រូវ |
|---|---|---|---|---|---|---|
| គ្រប់សកម្មភាពទាំងអស់ (១.១ ដល់ ៣.២) | សុខភាព និងសុវត្ថិភាពការងារជាទូទៅ (OHS) ជាពិសេសការប្រឈមនឹងការឆ្លងជំងឺកូវីដ-១៩ និង/ឬការចម្លងជំងឺ. កូវីដ-១៩ក្នុងអំឡុងសកម្មភាពគម្រោង (កិច្ចប្រជុំ ការបណ្តុះបណ្តាល ។ល។) | អ្នកចូលរួមក្នុងគម្រោងឆ្លងជំងឺកូវីដ-១៩ ឬជួបប្រទះនឹងបញ្ហាសុខភាព និងសុវត្ថិភាពការងារទាក់ទិននឹងការធ្វើដំណើររបស់ពួកគេ (ដូចជា គ្រោះថ្នាក់ចរាចរណ៍ជាដើម) | SES 3<br>SES 7 | L – 3<br>I – 3<br>S- មធ្យម | វិធានការការពារជំងឺកូវីដ-១៩ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាលកម្ពុជា និង WHO។ វិធានការទាំងនេះនឹងត្រូវបញ្ចូលជាវិធានការសុខភាព និងសុវត្ថិភាពការងារ (OHS) ទូទៅសម្រាប់គម្រោងក្នុងផែនការចូលរួមរបស់អ្នកពាក់ព័ន្ធគម្រោង (SEP)។ លើសពីនេះធានាឱ្យមានការអនុលោមតាមយុទ្ធសាស្រ្តស្តីពី OHS និង | UNDP ធានាថាវិធានការ OHS និងវិធានការការពារជំងឺកូវីដ-១៩ ត្រូវបានបញ្ចូលទៅក្នុងគ្រប់សកម្មភាពទាំងអស់របស់គម្រោង ។ |

[1] សមាសភាគមួយចំនួនត្រូវបានបញ្ចូលគ្នា ដោយសារតែវាមានហានិភ័យ/ផលប៉ះពាល់ស្រដៀងគ្នា។

[2] ផ្អែកតាមរូបភាពទី ១. L៖ លទ្ធភាពដែលអាចកើតមានឡើង (Likelihood) I៖ ផលប៉ះពាល់ (Impact) S៖ កម្រិតគួរឱ្យកត់សម្គាល់(Significance)

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | សុខុមាលភាព (OHSW) ២០២១-២៣ របស់ UNDP។ | |
| | ហានិភ័យ GBV/SH មានកម្រិតទាបសម្រាប់អ្នកចូលរួមពីសំណាក់អ្នកបណ្តុះបណ្តាល ឬអ្នកចូលរួមដទៃទៀតក្នុងអំឡុងពេលនៃសកម្មភាពគម្រោង (ការបណ្តុះបណ្តាល កិច្ចប្រជុំ ។ល។) | អ្នកចូលរួមក្នុងគម្រោង ជាពិសេសស្ត្រី គឺជាជនរងគ្រោះនៃ GBV/SH | SES 3<br>SES 7<br>គោលការណ៍ស្តីពីយេនឌ័រ និងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី | L – 2<br>I – 3<br>S- មធ្យម | អ្នកចូលរួម និងអ្នកបណ្តុះបណ្តាលទាំងអស់ដែលពាក់ព័ន្ធក្នុងគម្រោងនេះ គួរចុះហត្ថលេខាលើក្រមប្រតិបត្តិ (ដែលត្រូវបានបញ្ចូលទៅក្នុងឯកសារ SEP)។<br>អង្គការសហប្រជាជាតិនៅកម្ពុជា និងការិយាល័យ UNDP ប្រចាំប្រទេស មានផែនការសកម្មភាពស្តីពី SH/SEA និងមានព័ត៌មានអំពីជនបង្គោល និងការបណ្តុះបណ្តាលសម្រាប់បុគ្គលិក និងរដ្ឋាភិបាលអំពីបញ្ហាទាំងនេះ ព្រមទាំងឯកសារ និងការគាំទ្រដទៃទៀតដែលអាចយកមកប្រើប្រាស់បាន។<br>វគ្គបណ្តុះបណ្តាលដែលត្រូវបានកំណត់ជាកាតព្វកិច្ចសម្រាប់បុគ្គលិក និងដៃគូរបស់ UNDP គឺជាផ្នែកមួយនៃ | UNDP ធានាថាបុគ្គលិក និងអ្នកចូលរួមទាំងអស់ ពិតជាបានចុះហត្ថលេខាលើក្រមប្រតិបត្តិ GBV។ ការិយាល័យប្រចាំប្រទេសរបស់ UNDP បន្តអនុវត្តផែនការសកម្មភាពស្តីពី SH/SEA របស់ខ្លួន និងរាយការណ៍ទៅកាន់អគ្គលេខាធិការ តាមរយៈប្រធានអង្គការ UNDP (ដំណើរការបញ្ជាក់ប្រចាំឆ្នាំ)។ |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ផែនការសកម្មភាពប្រចាំឆ្នាំស្ដីពី SH/SEA។ | |
| | ការចូលរួមរបស់ស្ត្រីនៅមានកំណត់ | ស្ត្រីមិនអាចចូលរួមដោយស្មើភាពក្នុងសកម្មភាពរបស់គម្រោងបាន ដោយសារតែវិសមភាពយេនឌ័រដែលកំពុងមានស្រាប់។ | គោលការណ៍ស្ដីពីយេឌ័រ និងការលើកកម្ពស់ភាពអង់អាចរបស់ស្ត្រី | L – 3<br>I – 3<br>S – មធ្យម | គម្រោងនេះនឹងបន្តសហការជាមួយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងធានាឱ្យស្ត្រីបានចូលរួម។ សកម្មភាពរបស់គម្រោងនឹងមានការចូលរួមពីស្ត្រីយ៉ាងហោចណាស់ ៣៣% (ប៉ុន្តែគម្រោងគ្រោងនឹងបង្កើនដល់ ៥០%) | UNDP |
| | អ្នកចូលរួមក្នុងគម្រោងពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលបានព័ត៌មានរបស់គម្រោង | អ្នកចូលរួមមានលទ្ធភាពតិចតួចដើម្បីចូលរួមក្នុងគម្រោង និងទទួលបានប្រយោជន៍ពីគម្រោង ក៏ដូចជា អាចបង្ហាញពីការបារម្ភ ឬមតិយោបល់ជុំវិញសកម្មភាពរបស់គម្រោង។ | គណនេយ្យភាព | L – 3<br>I – 3<br>S- មធ្យម | គម្រោងគួរផ្ដួចផ្ដើមផ្សព្វផ្សាយព័ត៌មាន ដូចជា តាមរយៈការបន្តរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និងចូលរួមជាមួយអ្នកពាក់ព័ន្ធរបស់គម្រោង ក៏ដូចជាបង្ហាញព័ត៌មានគម្រោងដូចរៀបរាប់ក្នុងឯកសារ SEP។ | UNDP |
| ១.៣ រៀបចំឧបករណ៍ | ការរឹតត្បិតខ្លួនឯងក្នុងការបញ្ចេញមតិ | សមាសភាគរងដែលផ្ដោតលើការប្រកួតប្រជែងនៃធុរកិច្ចក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ | គោលការណ៍ស្ដីពីសិទ្ធិមនុស្ស | L – 3<br>I – 3<br>S- មធ្យម | គោលបំណងនៃការផ្ដល់ការគាំទ្រដល់ប្រព័ន្ធផ្សព្វផ្សាយឱ្យផលិតព័ត៌មាន ដែលបំផុសការ | UNDP |

| | | | | | | |
|---|---|---|---|---|---|---|
| និងអភិវឌ្ឍចំណេះដឹងដើម្បីឈ្វេងយល់ពីប្រយោជន៍របស់ពលរដ្ឋជាបុរស និងស្ត្រី Media Start-ups (i) | ភាពស្របច្បាប់របស់រដ្ឋាភិបាល<br>ជនជាតិដើមភាគតិច | អាចនាំឱ្យមានការរឹតត្បិតខ្លួនឯងមិនឱ្យបញ្ចេញមតិ (self-censorship) ព្រោះការភ័យខ្លាចទទួលរងការតបត និងត្រូវបានរដ្ឋាភិបាលប្រើប្រាស់ ដើម្បីបញ្ជាក់ថាប្រព័ន្ធផ្សព្វផ្សាយនៅក្នុងប្រទេសបានទទួលការគាំទ្រយ៉ាងសកម្ម។ | និងគណនេយ្យភាព SES 6 | | ចូលរួមនៅក្នុងសង្គម អាចនាំឱ្យប្រព័ន្ធផ្សព្វផ្សាយរឹតត្បិតខ្លួនឯងក្នុងការបញ្ចេញមតិ (ឬនាំឱ្យមានការតបត) និងផ្តល់ភាពស្របច្បាប់ដល់រដ្ឋាភិបាល។ គេអាចកាត់បន្ថយហានិភ័យនេះ តាមរយៈការធានានូវការសម្រេចចិត្តអំពីក្រុមទាំងឡាយណាដែលត្រូវផ្តល់ការគាំទ្រឱ្យ ដែលកំណត់ឡើងដោយ UNDP។ លើសពីនេះ ផែនការចូលរួម របស់អ្នកពាក់ព័ន្ធ (SEP) និងយន្តការដោះស្រាយបណ្តឹង (GRM) ដែលអាចទទួលបណ្តឹង (ដោយមានការរក្សាអនាមិកភាព) អាចជួយកាត់បន្ថយហានិភ័យនេះឱ្យនៅតិចជាអប្បបរមាក្នុងកម្រិតមួយជាក់លាក់។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យជុំវិញការរឹតត្បិតខ្លួនឯងក្នុងការបញ្ចេញមតិ (ឬការអាចមានការតបត) និងហានិភ័យជុំវិញ ការបង្កើតគុណសម្បត្តិអោយ រដ្ឋាភិបាល | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ទំនងនៅតែអាចបន្តមាន។ ជម្រើសមួយគឺត្រូវដកសកម្មភាពនេះចេញ ជាពិសេសដោយសារតែសកម្មភាពនេះនៅមិនទាន់មានថវិកាគាំទ្រនៅឡើយ។ | |
| ២.១ ផ្តល់អ្នកផ្សះផ្សារ និងអ្នកសម្របសម្រួល | ការផាត់ចេញក្រុមមួយចំនួនក្រុម ជនជាតិដើមភាគតិចភាពស្របច្បាប់របស់រដ្ឋាភិបាល | ក្រសួងមហាផ្ទៃដែលជាតំណាងនៅក្នុងក្រុមប្រឹក្សាភិបាលគម្រោង ប្រហែលជាមិនចង់ឱ្យបុគ្គលឬអង្គការដែលរដ្ឋាភិបាលចាត់ទុកថាជាក្រុមជំទាស់ ឬរិះគន់រដ្ឋាភិបាល ចូលរួមធ្វើជាអ្នកសម្របសម្រួល ឬអ្នកផ្សះផ្សានោះឡើយ ដែលធ្វើឱ្យដំណើរការសម្រុះសម្រួល/ផ្សះផ្សាអាចលម្អៀងទៅផ្នែកតែម្ខាង។ លើសពីនេះ បញ្ហាសំខាន់ៗមួយចំនួនអាចត្រូវបានគេផាត់ចេញពីការផ្សះផ្សា និង/ឬអ្នកសម្របសម្រួល/អ្នកផ្សះផ្សា អាចរឹតត្បិតខ្លួនឯងក្នុងការបញ្ចេញមតិដោយភ័យខ្លាចរដ្ឋាភិបាលតបតមកវិញ។ | គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងគណនេយ្យភាព SES 6 | L – 3<br>I – 3<br>S- មធ្យម | គេអាចកាត់បន្ថយហានិភ័យនេះឱ្យនៅជាអប្បបរមា ប្រសិនបើ UNDP ជាអ្នកជ្រើសរើសអ្នកសម្រុះសម្រួល/អ្នកផ្សះផ្សា។ លើសពីនេះ ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP) និងយន្តការដោះស្រាយបណ្តឹងដែលអាចទទួលយកពាក្យបណ្តឹងនានា (រួមទាំងបណ្តឹងអនាមិក) អាចជួយកាត់បន្ថយហានិភ័យនេះឱ្យនៅទាបជាអប្បបរមា។ អ្នកសម្របសម្រួល ក៏គួរចុះហត្ថលេខាលើក្រមសីលធម៌ផងដែរ។ ប៉ុន្តែហានិភ័យនានា ដូចជា ការរឹតត្បិតខ្លួនឯងក្នុងការបញ្ចេញមតិ ឬការអាចទទួលការតបត ឬហានិភ័យ | UNDP |

| | | | | | | |
|---|---|---|---|---|---|---|
| | | ការប្រើប្រាស់អ្នកសម្របសម្រួលអាចត្រូវបាន រដ្ឋាភិបាលអះអាងថាជា. ភស្តុតាងដែលបង្ហាញពីឆន្ទៈដើម្បីជំរុញការចូលរួមពីតួអង្គពាក់ព័ន្ធប្រកបដោយ អត្ថន័យ។ | | | ជុំវិញការបង្កើតនូវសម្បត្តិដល់រដ្ឋាភិបាល នៅតែបន្តមាន។ ខណៈពេលដែលសកម្មភាពគម្រោងត្រូវបានអនុវត្តក្នុងតំបន់ដែលមានជនជាតិដើមភាគតិច ភាពអនុលោមតាមស្តង់ដារ SES ទី ៦ របស់ UNDP ស្តីពីជនជាតិដើមភាគតិច រួមនឹងស្តង់ដារស្តីពីការផ្តល់ការយល់ព្រមដោយសេរីជាងមុន ផ្អែកតាមព័ត៌មានត្រឹមត្រូវ (FPIC)[3] ក្នុងករណីដែលពាក់ព័ន្ធ ក៏គួរជានាផងដែរ។ ជម្រើសមួយគឺត្រូវធ្វើនិយតកម្មថវិកាសម្រាប់សកម្មភាពនេះ។ | |
| ២.២ ធ្វើស្ថាប័ននីយកម្មហេដ្ឋារចនា. សម្ព័ន្ធដែលមានស្រាប់ សម្រាប់ការចូ | ការខកខានពុំបានបញ្ចូលអ្នកពាក់ព័ន្ធសំខាន់ៗ ជនជាតិដើមភាគតិច | ក្រុមមនុស្សមួយចំនួន (ជាពិសេសក្រុមសិទ្ធិមួយចំនួន) អាចត្រូវបានផាត់ចេញ (អាចផាត់ចេញដោយគម្រោង ឬពួកគេផាត់ចេញដោយខ្លួនឯង ) | គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងគណនេយ្យភាព SES 6 | L – 5<br>I – 4<br>S - ខ្ពស់ខ្លាំង | ហានិភ័យនេះពិបាកនឹងសម្រាល ដោយសារតែគោលជំហររបស់ក្រុមសិទ្ធិមនុស្សសំខាន់ៗដែលបានលើកឡើងថាពួកគេនឹងមិនចូលរួមក្នុងគម្រោងនេះឡើយ។ | UNDP |

---

[3] បើតាមស្តង់ដា SES ទី ៦ របស់ UNDP ត្រូវមានការរៀបចំកិច្ចពិគ្រោះយោបល់សមស្របទៅតាមវប្បធម៌ ក្នុងគោលដៅដើម្បីទទួលបានការឯកភាព និងត្រូវមានការធានាការអនុវត្តតាមគោលការណ៍ FPIC សម្រាប់បញ្ហាទាំងឡាយដែលអាចបង្កផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានដល់សិទ្ធិប្រយោជន៍ដីធ្លី ដែនដី (មិនថាមានប័ណ្ណកម្មសិទ្ធិ ឬក៏ពុំមានប័ណ្ណកម្មសិទ្ធិចំពោះសាមីជន) ធនធាន ជីវភាពរស់នៅបែបប្រពៃណី និង/ឬបេតិកភណ្ឌវប្បធម៌រូបីនិងអរូបីរបស់ជនជាតិដើមភាគតិច។

| | | | | | | |
|---|---|---|---|---|---|---|
| លរួមរបស់ពលរដ្ឋ និងគាំទ្រដល់ការអនុវត្តផែនការសកម្មភាព | | ពីយន្តការចូលរួមរបស់ពលរដ្ឋដែលទទួលបានការគាំទ្ររបស់គម្រោង ឬពីការចូលរួមក្នុងគណៈកម្មការបច្ចេកទេស។ ក្រុមសិទ្ធិមនុស្សដែលបានទទួលការគោរពមួយចំនួននៅកម្ពុជាបានលើកឡើងថាពួកគេនឹងមិនចូលរួមក្នុងគម្រោងឡើយ។ លើសពីនេះ បញ្ហាសិទ្ធិសំខាន់ៗត្រូវបានគេដកចេញពីកិច្ចពិគ្រោះយោបល់ប្រកប ដោយអត្ថន័យ ដោយរដ្ឋាភិបាល ឬដោយសារតែអ្នកចូលរួមរិតត្បិតខ្លួនឯងមិនឱ្យបញ្ចេញមតិ ដោយភ័យខ្លាចការតបត។ | | | គម្រោងអាចកាត់បន្ថយឱ្យនៅជាអប្បបរមា ឬសម្រាលយ៉ាងហោចណាស់ហានិភ័យមួយចំនួន តាមរយៈការបម្រួញគោលដៅនៃសមាសធាតុនេះ និង/ឬកែសម្រួលកម្មវិធីដែលទទួលបានការគាំទ្រ ដូចរៀបរាប់ខាងផ្នែក ៤.៣។ លើសពីនេះ ផែនការចូលរួមរបស់អ្នកពាក់ព័ន្ធ (SEP) និងយន្តការដោះស្រាយបណ្តឹង (GRM) ដែលអាចទទួលបណ្តឹង (រាប់បញ្ចូលទាំងបណ្តឹងអនាមិក) អាចជួយសម្រាលហានិភ័យនេះឱ្យនៅជាអប្បបរមាក្នុងកម្រិតមួយ។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យជុំវិញការរឹតត្បិតខ្លួនឯងក្នុងការបញ្ចេញមតិ ឬការទទួលការតបត និងការផាត់ចេញក្រុមមួយចំនួន (រួមនឹងការផាត់ចេញខ្លួនឯងផងដែរនោះ) ទំនងជានៅតែបន្តមាន។ ខណៈពេលដែលសកម្មភាពគម្រោងត្រូវបានអនុវត្តក្នុងតំបន់ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | ដែលមានជនជាតិដើមភាគតិចភាពអនុលោមតាមស្តង់ដារ SES ទី ៦ របស់ UNDP ស្តីពីជនជាតិដើមភាគតិច រួមនឹងស្តង់ដារស្តីពីការផ្តល់ការយល់ព្រមដោយសេរីជាមុនផ្អែកតាមព័ត៌មានត្រឹមត្រូវ (FPIC)[4] ក្នុងករណីដែលពាក់ព័ន្ធ ក៏គួរធានាផង ដែរ។ ជម្រើសមួយគឺត្រូវធ្វើនិយតកម្មថវិកាសម្រាប់សកម្មភាពនេះ។ | |
| | រដ្ឋាភិបាលទទួលបានភាពស្របច្បាប់ | តាមរយៈការគាំទ្រដល់វេទិកានិងកិច្ចពិគ្រោះយោបល់នានា គម្រោងនេះផ្តល់សុពលភាពដល់លំហដែលមានស្រាប់សម្រាប់ការចូលរួមរបស់ពលរដ្ឋនៅកម្ពុជា។ | គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងគណនេយ្យភាព | L – 4<br>I – 4<br>S -<br>ខ្ពស់មធ្យម। | ដូចខាងលើ | |

[4] បើតាមស្តង់ដា SES ទី ៦ របស់ UNDP ត្រូវមានការរៀបចំកិច្ចពិគ្រោះយោបល់សមស្របទៅតាមវប្បធម៌ ក្នុងគោលដៅដើម្បីទទួលបានការឯកភាព និងត្រូវមានការធានាការអនុវត្តតាមគោលការណ៍ FPIC សម្រាប់បញ្ហាទាំងឡាយដែលអាចបង្កផលប៉ះពាល់វិជ្ជមាន ឬអវិជ្ជមានដល់សិទ្ធិប្រយោជន៍ដីធ្លី ដែនដី (មិនថាមានប័ណ្ណកម្មសិទ្ធិ ឬក៏ពុំមានប័ណ្ណកម្មសិទ្ធិចំពោះសាមីជន) ធនធាន ជីវភាពរស់នៅបែបប្រពៃណី និង/ឬបេតិកភណ្ឌវប្បធម៌រូបីនិងអរូបីរបស់ជនជាតិដើមភាគតិច។